# រឿង

# ទីណូ ស្រេច និង ផ្លែត្រសក់



ឆ្នាំ ២០១០

អ្នកនិពន្ធ : លោកស្រី តឹក ស៊ីផុន
: លោកស្រី យឹម ចាន់ស្រី
អ្នករៀបរៀង : លោកស្រី ហួត សេយ៉ោន
វិចិត្រករ : លោក ឯម សត្យា

បានទទួលការអនុញ្ញាតឱ្យបោះពុម្ពផ្សាយពីក្រសួងអប់រំ សេចក្ដីសម្រេចលេខ ១៣៨ អរ.សសរ.
ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៩០ ដើម្បីប្រើប្រាស់នៅតាមសាលារៀនមត្តេយ្យ

គ្រឹះស្ថានបោះពុម្ពផ្សាយអប់រំ

បោះពុម្ពលើកទី១ ចំនួន៥,000ក្បាល
រោងពុម្ពក្រសួងអប់រំ ឆ្នាំ១៩៩១

អំណោយ អ៊ុយនីសែហ្វ
DON DE L'UNICEF

បោះពុម្ពលើកទី២ដោយ : អង្គការគាំពារកុមារខ្មែរ (CYK)
ភ្នំពេញ ខែកក្កដា ឆ្នាំ២០១០
មូលនិធិ : ប្រាក់សន្សំរបស់អ្នកចូលរួមទាំងអស់នៅប្រៃសណីយ៍ជប៉ុនសម្រាប់ជំនួយស្ម័គ្រចិត្តអន្តរជាតិ
ចំនួន : ៥,000ក្បាល
លេខ : CYK N10010
រោងពុម្ព : **J S R C** Printing House



ថ្ងៃនេះជាថ្ងៃអាទិត្យ ស្រូចកូនកណ្ដុរនឹកចង់ដើរលេងកម្សាន្ត ឯចម្ការ។ ស្រូចចេញពីផ្ទះពីព្រលឹមទៅបបួលទីណូ។ ទីណូទាញយកមួកហាមធំមកពាក់ រួចដើរចេញទៅជាមួយស្រូច។



ទីណូសួរស្រូចថា៖ "យើងនាំគ្នាទៅលេងឯណា?" ស្រូច ឆ្លើយ៖ "យើងនាំគ្នាទៅលេងឯចម្ការ។ ខ្ញុំឮថាចម្ការ លោកតាអែម មានដាំល្ពៅ ឪឡឹក ត្រឡាច ត្រសក់ ច្រើនណាស់។ មកយើងទៅចម្ការលោកតាអែមរកត្រសក់ហូប"។ ទីណូនិងស្រូច កាន់ដៃគ្នា ដើរបណ្ដើរច្រៀងបណ្ដើរ៖

"ចម្ការយើងស្រស់បំព្រង ត្រសក់ដំឡូង ឪឡឹកត្រឡាចចេញផ្កាមានផ្លែបាចសាច (ពីរដង) ល្ពៅត្រឡាចវារគងលើគ្នា។ យើងដាំ! យើងដាំ! យើងដាំ! យើងដាំ! យើងដាំ! យើងដាំ!"។



ទន្សាយ... 

ច្រៀងចប់ស្រួចនិយាយ៖ “ដល់ចម្ការតាអែមហើយ តែមិនឃើញគាត់សោះ ទីណ្ហូឯងជួយស្រែកហៅគាត់មើល”។ ទីណ្ហូស្រែកហៅ៖ “លោកតា! លោកតា! លោកតានៅឯណា?” គ្មានសំឡេងអ្វីឆ្លើយសោះ”។



ស្រួចក្រឡេកឃើញត្រសក់ធំៗ ខ្ចួតៗ គួរឱ្យស្រក់ទឹកមាត់។ ស្រួចចង់បេះត្រសក់ហូបក៏និយាយ៖ "រកតាមិនឃើញអញ្ចឹង ហើយបេះត្រសក់នេះហូបទៅ! មក! យើងបេះហូប"។



ទីណូចាប់ដៃស្រួចមិនឱ្យបេះរួចនិយាយថា៖ "ឈប់! កុំអាលបេះ មិត្តឯងបេះមិនបានប្រាប់ម្ចាស់គេអញ្ចឹង គឺលួចគេហើយ។ យើងដើរទៅចុងចម្ការខាងណោះរកលោកតាម្តងទៀតសិន"។ និយាយចប់ ទីណូអូសដៃមិត្តស្រួចដើរសំដៅចុងចម្ការ ហើយក៏បានជួបលោកតាអែម នៅទីនោះ។



តាអែមសួរថា៖ "អើចៅទាំងពីរមកចម្ការតាធ្វើអ្វីហ្នឹងហ្អា៎?" ទីណូនិងស្រួចឆ្លើយ៖ "ខ្ញុំមករកត្រសក់លោកតាហូប តែមិនឃើញលោកតា ខ្ញុំមិនហ៊ានបេះ"។

លោកតាអែមឆ្លើយៈ "អើល្អហើយចៅ! កុំយករបស់គេមិនបានប្រាប់ម្ចាស់គេណ៎ា គេថាយើងចោរណាចៅ! ហ្ន៎បេះទៅ! ចង់ហូបអីបេះហូបទៅចៅ តែចៅទាំងពីរដើរឱ្យល្អណា ប្រយ័ត្នដើរជាន់ដើមត្រសក់"



ទីណូនិងស្រូចបេះត្រសក់ហូបបណ្ដើរ ច្រៀងជូនលោកតាស្ដាប់បណ្ដើរនូវបទ "ចម្ការយើង"។

"ចម្ការយើងស្រស់បំព្រង ត្រសក់ ដំឡូង ឪឡឹក ត្រឡាច ចេញផ្កាបោះផ្លែបាចសាច (ពីរដង) ល្ពៅត្រឡាច វារគង លើគ្នា។ យើងដាំ យើងដាំ! យើងដាំ ៗ"។ ទីណូនិងស្រូច ហូបត្រសក់ឆ្អែត អរគុណលោកតា ហើយត្រឡប់ទៅផ្ទះវិញ យ៉ាងសប្បាយចិត្ត។



ក្រសួងអប់រំ យុវជន និងកីឡា
នាយកដ្ឋានអប់រំកុមារតូច

CYK

This aid project is supported by all participants in Japan's
Postal Saving for International Voluntary Aid.
និងអង្គការគាំពារកុមារខ្មែរ ( CYK )

9789996317095